អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៩**

# សេចក្តីប្រកាសព័ត៌មាន
# កិច្ចប្រជុំពេញអង្គលើកទី ៦ របស់ អ.វ.ត.ក
# ចាប់ផ្តើមនៅថ្ងៃច័ន្ទ ទី៧ ខែកញ្ញា ឆ្នាំ២០០៩

នៅចន្លោះពីថ្ងៃទី៧ ដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ អ.វ.ត.ក នឹងបើកកិច្ចប្រជុំពេញអង្គលើកទី ៦ នៅក្នុងសាលសវនាការរបស់ អ.វ.ត.ក ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ៤ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

កិច្ចប្រជុំពេញអង្គនេះនឹងពិភាក្សាអំពីសំណើសុំឲ្យធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងដំណើរការនៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ក្នុងចំណោមនោះរួមមាន វិធាននានាទាក់ទងនឹងវិធានការការពារ វិធានស្តីពីភស្តុតាង កាលបរិច្ឆេទកំណត់សម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី វិធានការរៀបចំឡើងដើម្បីធ្វើឲ្យកិច្ចដំណើរការនីតិវិធីមានភាពឆាប់រហ័ស នៅពេលដែលមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ និងនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ នៅមុនការចាប់ផ្តើមដំណើរការលើសំណុំរឿង ០០២ កិច្ចប្រជុំពេញអង្គនេះក៏នឹងពិភាក្សាសេចក្តីណែនាំដែលបានស្នើសុំឲ្យមានការកែប្រែទៅលើគំរូបច្ចុប្បន្ននៃការចូលរួមរបស់ជនរងគ្រោះផងដែរ។ ការពិភាក្សាដែលនឹងត្រូវបានកំណត់ត្រឹមតែទៅលើទស្សនទាននេះ នឹងស្នើសុំឲ្យមានអាណត្តិមួយដើម្បីសម្រួលដល់គំរូចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនាពេលបច្ចុប្បន្ន ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ និងបរិបទកម្ពុជាជាក់លាក់។

បណ្ដាញសារព័ត៌មានត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងការបើកកិច្ចប្រជុំពេញអង្គ ដែលនឹងចាប់ផ្ដើមនៅវេលាម៉ោង ១០ ព្រឹក នាថ្ងៃច័ន្ទ ទី៧ ខែកញ្ញា នៅក្នុងសាលសវនាការរបស់ អ.វ.ត.ក។ សុន្ទរកថាបើកនឹងត្រូវថ្លែងដោយប្រធាននៃកិច្ចប្រជុំពេញអង្គ ឯ.ឧ គង់ ស្រ៊ីម និងអនុប្រធាននៃកិច្ចប្រជុំពេញអង្គ លោកស្រីចៅក្រមអន្តរជាតិ Silvia Cartwright។

សេចក្ដីប្រកាសព័ត៌មានបន្ថែមនឹងត្រូវចេញនៅពេលបិទបញ្ចប់កិច្ចប្រជុំពេញពេញអង្គ នៅថ្ងៃសុក្រ ទី១១ ខែកញ្ញា ឆ្នាំ២០០៩។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក រាជ សម្បត្តិ
ប្រធានផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក
ទូរសព្ទដៃលេខ +៨៥៥-១២ ៤៨៨ ១៥៦
Fax: +855-23 219 841
អ៊ីមែល: reach.sambath@eccc.gov.kh

លោក ឌឹម សុវណ្ណរ៉ុំ
មន្ត្រីទទួលបន្ទុកផ្នែកព័ត៌មាននៃ អ.វ.ត.ក
ទូរសព្ទដៃលេខ +៨៥៥-១២ ៤៨៨ ០៩៤
ទូរសព្ទលើតុ +៨៥៥-២៣ ២១៩ ៨១៤
អ៊ីមែល: dim.sovannarom@eccc.gov.kh

លោក Lars Olsen
មន្ត្រីផ្នែកទំនាក់ទំនងផ្នែកច្បាប់នៃ អ.វ.ត.ក
ទូរសព្ទដៃលេខ +៨៥៥ (0) ១២ ៤៨៨ ០២៣
ទូរសព្ទលើតុ +៨៥៥ (0) ២៣ ២១៩ ៨១៤ ext. ៦១៦៩
អ៊ីមែល: olsenl@un.org

លោកស្រី Yuko Maeda

មន្ត្រីផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក
ទូរសព្ទដៃលេខ +៨៥៥-១២ ៤៨៨ ៣១៩
ទូរសព្ទលើតុ +៨៥៥-២៣ ២១៩ ៨១៤  ext. ៦១៣៩
អ៊ីមែល: maeday@un.org